**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
អគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក

សេចក្តីប្រកាសព័ត៌មាន

# កម្ពុជា និងថៃ បញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រ

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវ ផែថងថាន ស៊ីណាវ៉ាត្រា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាពង្រឹងបន្ថែមទៀតនូវមិត្តភាពយូរអង្វែង និងភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ អំឡុងពេលជំនួបទ្វេភាគីនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤ នាឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤ និង៤៥ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅរដ្ឋធានីវៀងចន្ទន៍។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសម្តែងនូវការអបអរសាទរយ៉ាងកក់ក្តៅសាជាថ្មី ចំពោះ **លោកជំទាវ ផែថងថាន ស៊ីណាវ៉ាត្រា** ដែលត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីថៃ នាពេលថ្មីៗនេះ។ នាយករដ្ឋមន្ត្រីទាំងពីរទន្ទឹងរង់ចាំការរៀបចំសកម្មភាពរួមគ្នាប្រកបដោយអត្ថន័យ ដើម្បីអបអរខួបអនុស្សាវរីយ៍លើកទី៧៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងថៃ នៅឆ្នាំ២០២៥ ខាងមុខ។

ចំពោះកិច្ចសហប្រតិបត្តិការនយោបាយ ថ្នាក់ដឹកនាំទាំងពីរបានគូសបញ្ជាក់អំពីសារសំខាន់នៃការផ្លាស់ប្តូរដំណើរទស្សនកិច្ច និងកិច្ចពិគ្រោះយោបល់កម្រិតខ្ពស់ជាទៀងទាត់ ដើម្បីស្វែងរកវិធី និងមធ្យោបាយធ្វើឱ្យកាន់តែស៊ីជម្រៅ និងពង្រីកបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី។ ក្នុងន័យនេះ ភាគីទាំងពីរពិចារណារៀបចំកិច្ចប្រជុំចង្អៀតគណៈរដ្ឋមន្ត្រីចម្រុះ និងលើកទឹកចិត្តឱ្យក្រសួងការបរទេសនៃប្រទេសទាំងពីររៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី ឱ្យបានឆាប់។

ក្នុងវិស័យសេដ្ឋកិច្ច ថ្នាក់ដឹកនាំទាំងពីរបានកត់សម្គាល់ដោយពេញចិត្តចំពោះកំណើនពាណិជ្ជកម្មទ្វេភាគី និងការផ្លាស់ប្តូរធុរកិច្ច។ ភាគីទាំងពីរបានស្វាគមន៍ចំពោះជោគជ័យនៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទេសចរណ៍លើកទី៣ កាលពីខែកក្កដា ឆ្នាំនេះ នៅទីក្រុងបាងកក និងចំពោះទស្សនទាន «**ព្រះរាជាណាចក្រពីរ គោលដៅតែមួយ**» ដើម្បីទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនទៅកាន់ប្រទេសទាំងពីរ។ ថ្នាក់ដឹកនាំទាំងពីរបានឯកភាពជំរុញឱ្យស្ថាប័នពាក់ព័ន្ធពន្លឿនគម្រោង

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 3[illegible]
អ៊ីម៉ែល : mfaic@mfaic.gov.kh

កិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ដើម្បីសម្រួលការដោះដូរពាណិជ្ជកម្មឆ្លងដែន ការជំរុញទេសចរណ៍ និងការកសាងភាពបំពេញឱ្យគ្នាទៅវិញទៅមក ដូចជាតាមរយៈការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅតាមបណ្តាខេត្តជាប់ព្រំដែន ដើម្បីផលប្រយោជន៍ទៅវិញទៅមកសម្រាប់ប្រជាជាតិទាំងពីរ។ ថ្នាក់ដឹកនាំទាំងពីរបានទទួលស្គាល់អំពីតួនាទីយ៉ាងសំខាន់ និងការចូលរួមយ៉ាងសកម្មរបស់វិស័យឯកជនក្នុងការជំរុញពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ។

ក្នុងគោលដៅលើកកម្ពស់សន្តិសុខ និងសុវត្ថិភាព ថ្នាក់ដឹកនាំទាំងពីរបានប្តេជ្ញាសហការជិតស្និទ្ធក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដូចជា ការរត់ពន្ធគ្រឿងញៀនខុសច្បាប់ ការជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអ៊ីនធឺណែត និងការគំរាមកំហែងសន្តិសុខសាយប័រ។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានទទួលយកដោយរីករាយនូវការអញ្ជើញរបស់ **លោកជំទាវនាយករដ្ឋមន្ត្រី** ទៅបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រថៃ និងបានអញ្ជើញ**លោកជំទាវនាយករដ្ឋមន្ត្រី** មកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជាផងដែរ។ **លោកជំទាវនាយករដ្ឋមន្ត្រី ផែថងថាន ស៊ីណាវ៉ាត្រា** បានទទួលយកការអញ្ជើញដោយពេញចិត្ត ហើយរំពឹងថានឹងអញ្ជើញបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងពេលដ៏ឆាប់ខាងមុខ៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រដ្ឋធានីវៀងចន្ទន៍ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤